ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:...៣៤៤៣.....PC អ.ក

# សេចក្ដីជូនដំណឹង

ស្ដីពីការផ្គត់ផ្គង់សម្ភារអគ្គិសនីចំនួន ០៧មុខ និងឈ្នួលពលកម្មការវិនិយោគពង្រីកខ្សែ
បណ្ដាញអគ្គិសនីជូនប្រជាពលរដ្ឋចំនួន ៣៣គ្រួសារ និង ៤៧គ្រួសារ នៅភូមិចាក់ជ្រូក
និង ភូមិចំការស្បែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យ បានជ្រាបថា: អគ្គិសនីកម្ពុជា និង ដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារស្ដីពី ការផ្គត់ផ្គង់សម្ភារអគ្គិសនីចំនួន ០៧មុខ និងឈ្នួលពលកម្មការវិនិយោគពង្រីកខ្សែបណ្ដាញអគ្គិសនីជូនប្រជាពលរដ្ឋចំនួន ៣៣គ្រួសារ និង ៤៧គ្រួសារ នៅភូមិចាក់ជ្រូក និង ភូមិចំការស្បែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បី ចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋាន៖ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពី ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទំនាក់ទំនង៖023 67 66 007 និង Website: www.edc.com.kh)។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១១ : ០០ នាទី។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥:១៥ នាទី។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ.........១៤.......ខែ.......ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី...២០....ខែ.......ឆ្នាំ២០២០
ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់_ធួច

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ